ទូរស័ព្ទ: 023 214 314-17
អ៊ីម៉ែល:advertising@phnompenhpost.com
www.phnompenhpost.com

# ប៉ុស្តិ៍យានយន្ត

ទូរស័ព្ទ: 023 214 314-17
អ៊ីម៉ែល:advertising@phnompenhpost.com
www.postkhmer.com

ថ្ងៃសុក្រ ទី៦ ខែធ្នូ ឆ្នាំ២០១៩
WWW.POSTKHMER.COM




## PORSCHE បង្ហាញរថយន្តថ្មី CAYENNE COUPÉ

## CHEVROLET SUBURBAN រថយន្តដ៏ប្រណីត



# PORSCHE បង្ហាញរថយន្តថ្មី CA



Porsche កំពុងពង្រីកសមាជិកគ្រួសារ Cayenne របស់ខ្លួន។ រថយន្ត Cayenne Coupé ជារថយន្តដែលមានរូបរាងកាន់តែស៊ីវិល័យ និងស្ព័រជាងមុន ត្រូវបានដាក់បញ្ចូលក្នុងប្រភេទ រថយន្ត Cayenne ជំនាន់ទី3។ លោក Oliver Blume ប្រធានក្រុមប្រឹក្សាប្រតិបត្តិ នៃ Porsche អាល្លឺម៉ង់ បានមាន ប្រសាសន៍ថា៖«ម៉ូដែល Coupé នេះបំពាក់បច្ចេកទេសគ្រប់យ៉ាងទាំងអស់របស់ Cayenne ប៉ុន្តែជាមួយនឹងការរចនារូបរាងកាន់តែលេចធ្លោ និងបច្ចេកវិទ្យាកាន់តែទំនើប ដែលធ្វើឲ្យរថយន្តនេះប្រៀបបានទៅនឹងអត្តពលិកមួយរូបដែលពោរពេញទៅដោយថាមពល»។

ម៉ូដែលថ្មីក្នុងអម្បូររបស់ Cayenne នេះ បានលេចចេញនូវខ្សែបន្ទាត់ច្បាស់ជាងមុន ហើយផ្នែកខាងក្រោយនៃតួរថយន្ត កាន់តែមានលក្ខណៈពិសេសជាមួយនឹង Adaptive rear spoiler រីឯកៅអីខាងក្រោយមានលក្ខណៈប្លែកជាងមុន ហើយចំពោះដំបូលរថយន្ត អតិថិជនមានជម្រើសក្នុងការកុម្ម៉ង់យកដំបូលកាបូន ឬដំបូលផ្ទាំងកញ្ចក់។ ខ្សែបន្ទាត់ដំបូលដែលមានជម្រាលជ្រៅ បង្កើតភាពឆើតឆាយដែលមិនមានការប្រកួតប្រជែង។

សមាមាត្រដែលកាន់តែមានភាពរស់រវើក រួមផ្សំជាមួយការរចនាផ្ទាល់ខ្លួន បានធ្វើឲ្យ Cayenne Coupé ថ្មី ប្រកបដោយភាពឆើតឆាយ។

លោក Michael Mauer អនុប្រធានផ្នែករចនារបស់ Porsche បានលើកឡើងថា៖«ខ្សែដំបូលដែលមានលក្ខណៈចោតកាន់តែជ្រៅទៅផ្នែកខាងក្រោយ ធ្វើឱ្យរថយន្ត Cayenne Coupé មើលទៅកាន់តែមានភាពរឹងមាំ ហើយបានចាត់ទុកវាជាម៉ូដែលមើលទៅគួរឲ្យទាក់ទាញបំផុតនៅក្នុងផ្នែកនេះ។

ដំបូលកញ្ចក់បែប Panoramic ដែលមានទំហំធំត្រូវបានបំពាក់ជាស្តង់ដាជាមួយនឹងជម្រើសដំបូលកាបូន។



Cayenne Coupé ថ្មីភ្ជាប់មកជាមួយដំបូលកញ្ចក់ដែលមានទំហំរហូតដល់ 2.16 m² និងបានបំពាក់ជាលក្ខណៈស្តង់ដា។ តំបន់ដែលអាចឲ្យអ្នកដំណើរមើលឃើញពន្លឺព្រះអាទិត្យ និងលម្ហខាងលើមានទំហំ 0.92 m² និងបានភ្ជាប់មកជាមួយនឹងវាំងននការពារកម្តៅថ្ងៃ ពន្លឺព្រះអាទិត្យ និងភាពត្រជាក់បានទៀតផង។ ពិសេសជាងនេះទៅទៀត អតិថិជនក៏អាចកុម្ម៉ង់យកដំបូលកាបូន ជំនួសឲ្យដំបូងកញ្ចក់បានផងដែរ ។

Cayenne Coupé ថ្មីផ្តល់កន្លែងទំនេរច្រើនសម្រាប់មនុស្សរហូតដល់ 4នាក់ ដែលមានលក្ខណៈស្តង់ដា។ នៅផ្នែកខាងមុខកន្លែងអង្គុយបែបស្ព័រ ដែលអាចផ្លាស់ប្តូរទម្រង់អង្គុយបានរហូតដល់ 8 បែប នឹងផ្តល់នូវផាសុកភាពយ៉ាងពិសេសសម្រាប់អ្នកដំណើរ។

រីឯផ្នែកខាងក្រោយអាចផ្ទុកចំណុះរហូតដល់ 625 លីត្រ ដែលល្អបំផុតសម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃ និងកើនឡើងដល់ 1,540 លីត្រនៅពេលកៅអីខាងក្រោយបត់ចុះក្រោម (Cayenne Turbo Coupé 600 ទៅ 1,510 លីត្រ ) ។

មានជម្រើសម៉ាស៊ីន2បែប គឺ 340 PS និង 550 PS turbocharged ។

ម៉ាស៊ីនដែលមានសមត្ថភាពខ្ពស់ចំនួន2របស់ Cayenne Coupé គឺទី1 មានម៉ាស៊ីន6 ស៊ីឡាំងចំណុះ3 លីត្រផ្តល់នូវកម្លាំង ២៥០គីឡូវ៉ាត់ (340 PS) និងកម្លាំងបង្វិលអតិបរមា 450Nm កញ្ចប់ Sport Chrono ដែលត្រូវបានបំពាក់នៅក្នុងយានយន្តអាចសម្រេចបាននូវល្បឿនពី 0 - 100គ.ម/ម៉ ក្នុងរយៈពេល 6 វិនាទី








# AYENNE COUPÉ



ដោយតួលេខនេះ ធ្លាក់ចុះដល់ 5.9 វិនាទីជាមួយនឹងកញ្ចប់ទម្ងន់ស្រាល។ ល្បឿនល្បឿនបំផុតរបស់រថយន្តគឺ 243 គ.ម/ម៉ ។

ជួរកំពូលរបស់ Cayenne Turbo Coupé ចាប់ផ្តើមជាមួយនឹងម៉ាស៊ីន V8 ចំណុះ4 លីត្រជាមួយនឹងសាកថ្មភ្លោះ 404 គីឡូវ៉ាត់ (550 PS), និងកម្លាំងបង្វិលអតិបរមា 770 Nm។ Cayenne Turbo Coupé បង្កើនល្បឿនពី 0 - 100គ.ម/ម៉ ក្នុងរយៈពេល 3.9 វិនាទីនិងមានល្បឿនអតិបរមា 286 គ.ម/ម៉។

Cayenne Coupé កម្រិតប្រើប្រាស់ប្រេងឥន្ធនៈ 9.4 – 9.3 l/100 គ.ម ការបំភាយឧស្ម័ន CO2 : 215 – 212 ក្រាម/គ.ម ។

Cayenne Turbo Coupé កម្រិតប្រើប្រាស់ប្រេងឥន្ធនៈ 11.4 – 11.3 l/100 km; ការបំភាយឧស្ម័ន CO2 :261 – 258 /គ.ម៕




## អំពីមជ្ឈមណ្ឌល Porsche ភ្នំពេញ

ដោយមានទីតាំង ស្ថិតនៅទល់មុខអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងស្ថិតនៅតាមបណ្តោយមហាវិថីសហព័ន្ធរុស្ស៊ី មជ្ឈមណ្ឌល Porsche ភ្នំពេញ គឺជាហាងថ្មីបំផុត និងទំនើបបំផុតមួយនៅក្នុងប្រទេសកម្ពុជា។ មជ្ឈមណ្ឌល Porsche ភ្នំពេញ មានបន្ទប់តាំងបង្ហាញរថយន្តថ្មីទំហំ 500 ម៉ែត្រការ៉េដ៏គួរឲ្យចាប់អារម្មណ៍ និងទីតាំងផ្តល់សេវាក្រោយការលក់មានទំហំរហូតដល់ 700 ម៉ែត្រការ៉េ។ មជ្ឈមណ្ឌល Porsche ភ្នំពេញ បម្រើការជាទីតាំងផ្តល់សេវាច្រើនមុខ ដែលមានចាប់ពីការលក់ សេវាក្រោយការលក់ សម្ភារបន្ទាប់បន្សំ ( បរិក្ខារបច្ចេកទេស ) ការផ្សព្វផ្សាយលក់រថយន្ត Porsche ( ការជ្រើសរើសរបស់អ្នកបើកបរ Porsche ) នៅក្នុងកន្លែងតែមួយ ដោយផ្តល់នូវកម្រិតសេវាខ្ពស់ដល់អតិថិជនរបស់ Porsche នៅក្នុងប្រទេសកម្ពុជា។ មជ្ឈមណ្ឌល Porsche ភ្នំពេញ ក៏ផ្តល់នូវម៉ូដែល Porsche ទាំងអស់ រួមទាំងការធ្វើឲមានលក្ខណៈផ្ទាល់ខ្លួនសម្រាប់ម៉ូដែល Porsche នីមួយៗផងដែរ៕ ■

NISSAN
Innovation that excites

NissanConnect AIVI

Nissan Connect A-IVI គឺជាប្រព័ន្ធភ្ជាប់ដើម្បីផ្តល់ព័ត៌មានទំនើបចុងក្រោយបំផុត ដែលអនុញ្ញាតឱ្យលោកអ្នកប្រើប្រាស់ជ្រើសរើសកម្មវិធីនៅក្នុងស្មាតហ្វូនរបស់ខ្លួនដោយផ្ទាល់តាមរយៈអេក្រង់ touchscreen របស់នីស្សាន់ ( ឧទាហរណ៍ពី Apple CarPlay )។
អេក្រង់ផ្តល់ព័ត៌មាននេះត្រូវបានរចនាប្រកបដោយភាពប្រណីត ទាន់សម័យ ជាមួយនឹងក្រាហ្វិកច្បាស់ល្អ ដែលជួយបង្កើនភាពទាក់ទាញដល់រថយន្តរបស់លោកអ្នកទ្វេដង។ អេក្រង់ touchscreen អាចបញ្ជាបានតាមរយៈកាយវិការច្រើនបែប មានភាពងាយស្រួល និងឆាប់រហ័ស សម្រាប់អ្នកបើកបរប្រើប្រាស់។





1- ផែនទីរស់រវើកដែលអាចមើលឃើញដំណើរចរាចរណ៍បានយ៉ាងច្បាស់ ( លោកអ្នកអាចប្រើកាយវិការច្រើនបែបដើម្បីពង្រីក និងបង្រួម )។
2- ប្រើសំឡេងបញ្ជាដើម្បីស្វែងរកព័ត៌មានតាមរយៈអេក្រង់ផ្តល់ព័ត៌មាន ( ឬគ្រាន់តែចុចពាក្យ type-away )។
3- បញ្ចូលបញ្ជីឈ្មោះបទចម្រៀងទាំងអស់របស់លោកអ្នក រួមទាំងសេវាអនឡាញដែលបានជ្រើសរើសដោយគ្រាន់តែចុចទៅលើអេក្រង់ផ្តល់ព័ត៌មានក្នុងរថយន្តរបស់លោកអ្នកប៉ុណ្ណោះ។
4- ផ្តល់ភាពងាយស្រួលពេលនិយាយទូរស័ព្ទ ដោយមិនចាំបាច់កាន់ទូរស័ព្ទនោះទេ លោកអ្នកគ្រាន់តែប្រើសំឡេងបញ្ជាជាការស្រេច។
5- អនុញ្ញាតឲ្យសំឡេងបញ្ជាអានសារដែលផ្ញើចូលក្នុងទូរស័ព្ទស្មាតហ្វូនរបស់លោកអ្នក និងដើម្បីឆ្លើយតប។
6- ប្រើសំឡេងដើម្បីស្វែងរកប៉ុស្តិ៍វិទ្យុដែលលោកអ្នកចូលចិត្ត។
7- អេក្រង់ផ្តល់ព័ត៌មាននេះអាចបញ្ជាបានតាមការចង់បានរបស់អ្នកប្រើប្រាស់។

* ប្រព័ន្ធនេះគឺប្រែប្រួលទៅតាមប្រទេសឬតំបន់នីមួយៗ

អតិថិជនអាចមកពិនិត្យមើល និងស្វែងយល់អំពីបច្ចេកវិទ្យា NissanConnect ដែលមានបំពាក់លើរថយន្ត Nissan Navara Premium Plus និងរថយន្ត Nissan Terra ។ លើសពីនេះទៀត អតិថិជនក៏អាចកក់ ឬធ្វើការបើកបរសាកល្បងរថយន្តនីស្សាន់ណាមួយនៅគ្រប់សាលតាំងបង្ហាញរថយន្តនីស្សាន់។

សម្រាប់ព័ត៌មានបន្ថែមអំពីម៉ូដែលរថយន្តនីស្សាន់ទាំងអស់នៅកម្ពុជា សូមលោកអ្នកចូលទៅកាន់គេហទំព័ររបស់ក្រុមហ៊ុននីស្សាន់កម្ពុជា តាមរយៈគេហទំព័រ www.nissan.com.kh/ ឬចូលទៅកាន់ទំព័រហ្វេសប៊ុករបស់ក្រុមហ៊ុននីស្សាន់ fb.com/CambodiaNissan/ ៕

ទទួលសិទ្ធិនាំចូល និងចែកចាយដោយ
TAN CHONG MOTOR (CAMBODIA) PTY. LTD.

ទទួលសិទ្ធិក្នុងការតាំងបង្ហាញ និងលក់ដោយ
សាខាភ្នំពេញ / ( ផ្លូវលេខ 271 ) 023 993 338, ( ផ្លូវលេខ 598 ) 098 470 446, ( ផ្លូវលេខ 857, 023 900 271 )
សាខាសៀមរាប / 063 966 588 / បាត់ដំបង / 053 953 688

/CambodiaNissan
www.nissan.com.kh

ពាណិជ្ជកម្មបង់ប្រាក់

# Chevrolet Suburban រថយន្តដ៏ប្រណីតនិងមានការច្នៃប្រឌិតខ្ពស់



រថយន្ត Suburban ផ្តល់ជូននូវអ្វីៗគ្រប់យ៉ាងដែលលោកអ្នកត្រូវការក្នុងនោះមានដូចជាភាពធំទូលាយ លំនឹងក្នុងការបើកបរ ដែលបំពាក់ដោយបច្ចេកវិទ្យាសុវត្ថិភាពខ្ពស់ រួមនឹងលក្ខណពិសេសៗជាច្រើនទៀត។ មិនថាលោកអ្នកបើកបរពេលយប់ ពេលថ្ងៃ ឬដំណើរកម្សាន្តចុងសប្តាហ៍ រថយន្ត Suburban ដ៏ទំនើបនេះបានត្រៀមខ្លួនជាស្រេចដើម្បីបំពេញរាល់តម្រូវការរបស់លោកអ្នក។ ហើយវាមិនមែនជាចម្ងល់នោះទេដែលថា រថយន្ត Chevrolet Suburban នេះគឺជាផ្នែកមួយនៃប្រភេទរថយន្ត SUV (full size) ដែលលក់ដាច់បំផុត ។

Suburban ត្រូវបានរចនាប្រកបដោយភាពទាក់ទាញ និងស្រស់ស្អាត។ តួរថយន្តត្រូវបានរចនាឡើងជាមួយនឹងភាពរឹងមាំ និងធន់បំផុត។ វាបំពាក់ដោយយ៉ាន់ស្ព័រអាលុយមីញ៉ូមទំហំ២០អ៊ិញ។ អតិថិជនក៏អាចជ្រើសរើសទំហំយ៉ាន់ស្ព័រទំហំ២០ឬ២២អ៊ិញបានផងដែរ។

កៅអីរថយន្ត Suburban ជួរទី២ និងជួរទី៣ អាចបត់បានដោយងាយស្រួល និងលឿនបំផុត ជាងគូប្រកួតប្រជែងណាៗទាំងអស់។ ប៊ូតុងត្រូវបានដាក់នៅក្នុងទីតាំងដែលងាយស្រួលចុច អ្នកធ្វើដំណើរងាយស្រួលក្នុងធ្វើការធ្វើចលនា។



ដោយសាតែកៅអីជួរទី២ និងទី៣ អាចបត់ចុះឲ្យរាបស្មើបាន ធ្វើឲ្យលោកអ្នកមានទីធ្លាធំទូលាយសម្រាប់ផ្ទុកទំនិញឬសម្ភារផ្សេងៗ។ ជាមួយនឹងបច្ចេកវិទ្យាទំនើប ធ្វើឲ្យការលើកទំនិញដាក់ឬចុះមានមានភាពងាយស្រួល។ ដូច្នេះហើយវាគ្មានអ្វីគួរឱ្យឆ្ងល់នោះទេ ដែលគេហទំព័រ KBB.com ឲ្យចំណាត់ថ្នាក់រថយន្ត Suburban ជារថយន្ត«10 Best Road Trip Cars of 2015»។

ស្តង់ដា LTZ ជួយសម្រួលដល់ការបើកទ្វារក្រោយដើម្បីដាក់ទំនិញ និងសម្ភារផ្សេងៗ ដោយមិនចាំបាច់ប្រើដៃ ដើម្បីធានាថាទោះបីលោកអ្នកកាន់ទំនិញច្រើនក្នុងដៃក៏គ្មានកង្វល់ដែរ ពីព្រោះសេនស័រនៅខាងក្រោមនឹងជួយបើកឃ្លុបទ្វារខាងក្រោយដោយស្វ័យប្រវត្តិដោយលោកអ្នកគ្រាន់តែលើកជើងទាត់ថ្នមៗប៉ុណ្ណោះ។

លើសពីនេះទៀត រថយន្ត Suburban គឺជារថយន្តដំបូងគេនៅក្នុងប្រភេទរបស់វា ដែលមានបំពាក់ Apple CarPlay™ ស្តង់ដា។ ប្រព័ន្ធនេះមានលក្ខណពិសេសមួយចំនួនរបស់ iPhone® ដែលលោកអ្នកអាចប្រើជាមួយយានយន្តរបស់លោកអ្នក-ដែលវាបង្ហាញពីភាពឆ្លាតវៃ និងងាយស្រួល។

ភ្ជាប់ទៅទូរស័ព្ទប្រើប្រាស់បានច្រើនបែប ដូចជាដើម្បីស្តាប់តន្ត្រីផ្ញើសារ ( ឧទាហរណ៍ iHeartRadio,2 Spotify2) ដែលគ្រប់គ្រងតាមរយៈប៊ូតុង៣ ឬក៏អាចគ្រប់គ្រងតាមរយៈអេក្រង់ touch screen នៅក្នុងរថយន្ត SUV របស់អ្នកផងដែរ។ លើសពីនេះទៀត លោកអ្នកអាចប្រើដើម្បីនិយាយទូរស័ព្ទ និងស្តាប់តន្ត្រីដើម្បីកម្សាន្តបានយ៉ាងងាយស្រួលគ្រប់ពេលវេលា(24/7)។

ចំពោះប្រព័ន្ធកម្សាន្តសម្រាប់អ្នកអង្គុយកៅអីខាងក្រោយ (Rear-Seat Blu-ray®) មានអេក្រង់២ ដែលអាចឱ្យអ្នកដំណើរដែលអង្គុយកៅអីខាងក្រោយរីករាយនឹងប្រព័ន្ធដ៏ទំនើបនេះ ដើម្បីទស្សនាភាពយន្តដែលពួកគេចូលចិត្ត ដូច្នេះមិនថាធ្វើដំណើរផ្លូវឆ្ងាយប៉ុនណាក៏លោកអ្នកនៅតែរីករាយ។

Chevrolet គឺជាក្រុមហ៊ុនរថយន្តដំបូងគេតែមួយគត់ដែលផ្តល់ជូននូវប្រព័ន្ធ 4G LTE Wi-Fi® ភ្ជាប់ជាមួយរថយន្ត និងផ្តល់នូវសមត្ថភាពក្នុងការភ្ជាប់ឧបករណ៍ឆ្លាតវៃ និងយានយន្តរបស់អ្នកទៅប្រព័ន្ធអ៊ីនធឺណិត។ នៅពេលណាដែលរថយន្ត Suburban របស់អ្នកត្រូវបានបញ្ឆេះនោះ 4G LTE Wi-Fi នឹងដំណើរការដោយស្វ័យប្រវត្តិដែរ។

លក្ខណពិសេសផ្សេងទៀតនៃរថយន្ត Suburban គឺប្រព័ន្ធ Corvette-inspired Magnetic Ride Control ជាប្រព័ន្ធជួយត្រួតពិនិត្យការបើកបរដោយម៉ាញេទិកធ្វើឲ្យការបើកបរ ប្រព្រឹត្តទៅដោយរលូន។

បច្ចេកវិទ្យា ការច្នៃប្រឌិតថ្មី ប្រព័ន្ធសុវត្ថិភាព ភាពធន់ ថាមពលប្រកបដោយប្រសិទ្ធភាព ធ្វើឲ្យរថយន្ត Chevrolet Suburban ក្លាយជាជម្រើសដ៏ស័ក្តិសមបំផុតសម្រាប់អ្នកស្រឡាញ់រថយន្តប្រណីត។ មិនថាលោកអ្នកធ្វើដំណើរនៅពេលណាឬទៅកាន់ទីកន្លែងណា រថយន្ត Suburban ដ៏ទំនើបនេះ ផ្តល់ជូននូវសុវត្ថិភាព និងផាសុកភាពខ្ពស់បំផុតដល់អ្នកដំណើរ គ្រប់ពេលវេលា និងគ្រប់ទីកន្លែង៕ ■





